**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តស្ទឹងត្រែង**
សំណុំរឿងព្រហ្មទណ្ឌលេខៈ១៧០
ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩
សាលក្រមលេខៈ ៤៨ (គ)
ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តស្ទឹងត្រែង

បានបើកសវនាការជាសាធារណៈ នៅសាលាដំបូងខេត្តស្ទឹងត្រែង នៅថ្ងៃទី២៩ ខែមករា ឆ្នាំ ២០២០ វេលាម៉ោង ៨:៣០នាទីព្រឹក និងប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ៩:០០ នាទីព្រឹក ដែលមានសមាសភាពដូចតទៅ ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តស្ទឹងត្រែង

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តស្ទឹងត្រែង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តស្ទឹងត្រែង

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ១៧០ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២០ ដែលមានជនជាប់ចោទៈ

-ឈ្មោះ [redacted] **សារី** ភេទប្រុស អាយុ ៥៧ ឆ្នាំ ជនជាតិខ្មែរ មុខរបរ កសិករ ទីកន្លែងកំណើតភូមិ [redacted] ខេត្តរតនៈគិរី ទីលំនៅបច្ចុប្បន្នភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ឪពុកឈ្មោះ [redacted] ខាំវ៉ាន់ (ស) ម្តាយឈ្មោះ [redacted] សើយភឹម (ស) ប្រពន្ធឈ្មោះ [redacted] ភាព មានកូនចំនួន ០៣ នាក់ ទោសពីមុនគ្មាន។

ត្រូវបានចោទប្រកាន់ពីបទៈ **ចែកចាយ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងកាន់កាប់អាវុធដោយខុសច្បាប់** ប្រព្រឹត្តនៅចំណុចក្នុងព្រៃក្រោយចំការម៉ៃសាក់ ស្ថិតនៅភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៩ បទល្មើសដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០, មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ។

-លោក [redacted] ជាមេធាវីការពារក្តីឱ្យជនជាប់ចោទ

**១.អង្គហេតុមានដូចតទៅ**



Scanned with CamScanner

រាជានុកូល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថាៈ ឆ្លងកាត់ការសាកសួរដេញដោលក្នុងសវនាការនេះ ឃើញថាជនជាប់ចោទឈ្មោះ [redacted] សារី បានឆ្លើយសារភាពហើយថាខ្លួនពិតជាប្រព្រឹត្តដូចដែលបានចោទប្រកាន់ពិតមែន។ ដូច្នេះ តំណាងអយ្យការយល់ឃើញថា មានពិរុទ្ធភាព និងភស្តុតាងគ្រប់គ្រាន់ក្នុងការដាក់បន្ទុកចោទប្រកាន់លើជនជាប់ចោទនេះ ពីបទៈ **ចែកចាយ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងកាន់កាប់អាវុធដោយខុសច្បាប់** ប្រព្រឹត្តនៅក្នុងព្រៃក្រោយចំការម៉ៃសាក់ ស្ថិតនៅភូមិរាជានុ កូល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង បទល្មើសដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ។ ដូច្នេះតំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ទុកជាបានការដដែល និងស្នើសុំតុលាការពិនិត្យ និងសម្រេចតាមច្បាប់។

-មេធាវីការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted] **សារី** បានធ្វើសេចក្តីសន្និដ្ឋានថាៈ ខ្លួនសុំធ្វើសេចក្តីសន្និដ្ឋានដូចតទៅ កូនក្តីរបស់ខ្លួនពិតបានប្រព្រឹត្ត និងបានសារភាព ព្រមទាំងទទួលនូវទោសកំហុសរបស់ខ្លួនប្រាកដមែន ដូច្នេះខ្លួនសូមឱ្យតុលាការផ្តល់ស្ថានសម្រាលទោសដល់កូនក្តីរបស់ខ្លួនផង។

- សំដីចុងក្រោយរបស់ជនជាប់ចោទឈ្មោះ [redacted] សារី បាននិយាយថាៈ សូមតុលាការជួយបន្ធូរបន្ថយទោសខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

**ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ**

**សាលាដំបូងខេត្តស្ទឹងត្រែង**

**-យល់ឃើញថា:** ជនជាប់ចោទឈ្មោះ [redacted] សារី ភេទប្រុស (មានសាវតាជាតិដូចខាងលើ) ត្រូវបានចៅក្រមស៊ើបសួរចោទប្រកាន់បញ្ជូនមកជំនុំជម្រះពីបទ: **ចែកចាយ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងកាន់កាប់អាវុធដោយខុសច្បាប់** ប្រព្រឹត្តនៅក្នុងព្រៃក្រោយចំការម៉ៃសាក់ ស្ថិតនៅភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង បទល្មើសដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ។

**-យល់ឃើញថា:** តាមរបាយការណ៍លេខ ១៣៥/១៩ របក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៩ របស់ស្នងការនគរបាលខេត្តស្ទឹងត្រែង បានបង្ហាញថានៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ១៦ និង ០០ នាទី មន្រ្តីអនុវត្តច្បាប់នៃការិយាល័យប្រឆាំងគ្រឿងញៀន បានបង្ក្រាបករណីជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដោយវិធានញុះញង់ ប្រព្រឹត្តនៅចំណុចក្នុងព្រៃក្រោយចំការម៉ៃសាក់ ស្ថិតក្នុងភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង ចាប់យកវត្ថុតាងថ្នាំញៀនប្រភេទមេតំហ្វេតាមីនក្រាមពណ៌សថ្លា (ICE) ចំនួន ០៩ កញ្ចប់តូច ទម្ងន់សរុប ២.៤ ក្រាម ឃាត់ខ្លួនជនសង្ស័យឈ្មោះ[redacted] សារី ភេទប្រុស អាយុ ៥៧ ឆ្នាំ ប្រាកដមែន។

**-យល់ឃើញថា:** ជនជាប់ចោទឈ្មោះ[redacted]សារី បានឆ្លើយសារភាពនៅគ្រប់ដំណាក់កាលថាៈ



Scanned with CamScanner

+កាំភ្លើងកែច្នៃចំនួន ០២ ដើម និងគ្រាប់កង់មួយចំនួន, គ្រាប់កាំភ្លើង AK ចំនួន ១០គ្រាប់, ដាវសាម៉ូរ៉ៃចំនួន០១ដើម ជាឧបករណ៍ដែលច្បាប់បានហាមឃាត់ គប្បីរឹបអូសបំផ្លាញចោល។

+ខ្សែកលោហៈធាតុពណ៌លឿងបណ្តោងព្រះចំនួន ០១ ខ្សែមិនមានការពាក់ព័ន្ធក្នុងបទល្មើស គប្បីប្រគល់ជូនម្ចាស់ដើមវិញ។

## ហេតុដូច្នេះសម្រេច

**១-ផ្តន្ទាទោសឈ្មោះ** [redacted] សារី ភេទប្រុស អាយុ ៥៧ ឆ្នាំ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់រយៈពេល ៣ (បី) ឆ្នាំ និង ៨ (ប្រាំបី)ខែ **គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ និងពិន័យជាប្រាក់ ៦.០០០.០០០៛** (ប្រាំមួយ) លានរៀល ដើម្បីបង់ចូលថវិការដ្ឋ គិតចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ។

ពីបទ៖ **ចែកចាយ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និងកាន់កាប់អាវុធដោយខុសច្បាប់** ប្រព្រឹត្តនៅក្នុងព្រៃក្រោយចំការម៉ៃសាក់ ស្ថិតនៅភូមិរាជានុកូល សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង បទល្មើសដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៤៩០ នៃក្រមព្រហ្មទណ្ឌ។

**២-វត្ថុតាងដែលដកហូតបានមាន៖** ថ្នាំញៀនប្រភេទមេតំហ្វេតាមីនចំនួន ០៩ គ្រាប់ ទម្ងន់សរុប ២.៤ ក្រាម រឹបអូសបំផ្លាញចោល។

+ទូរស័ព្ទចំនួន ០២ គ្រឿង ម៉ាក TREU និងម៉ាក BINGO, កាំភ្លើងកែច្នៃចំនួន ០២ ដើម និងគ្រាប់កង់មួយចំនួន, គ្រាប់កាំភ្លើង AK ចំនួន ១០ គ្រាប់, ដាវសាម៉ូរ៉ៃចំនួន ០១ដើម រឹបអូសបំផ្លាញចោល។

+ខ្សែកលោហៈធាតុពណ៌លឿងបណ្តោងព្រះចំនួន ០១ ខ្សែ ប្រគល់ជូនម្ចាស់ដើមវិញ គិតចាប់ពីថ្ងៃសាលក្រមចូលជាស្ថាពរ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ៨:៣០នាទីរសៀល និងប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង ៩:០០ នាទីព្រឹក ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] សារី។

**ទុកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់៕**

**សេចក្តីនេះព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលក្រម ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់គ្រប់តំណែង និងកម្លាំងប្រដាប់អាវុធជួយសហការណ៍អនុវត្តសាលក្រមនេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់៕**

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា
[redacted]

**ចៅក្រមប្រឹក្សា**
ហត្ថលេខា និងត្រា
[redacted]

---

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**
[redacted]

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ថ្ងៃ.........ខែ.........ឆ្នាំ.........ព.ស.........
ស្ទឹងត្រែង ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០២០
**ក្រឡាបញ្ជី**
[redacted]



Scanned with CamScanner